00609971

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
លេខ/No: D427/1/2
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 09 / 2010
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ / Public CA

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា នៅលើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រ ចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក ច័ន្ទ តារាស្មី
លោក Anees AHMED

**អ្នកទទួលឯកសារ:**
អង្គបុរេជំនុំជម្រះ:

**មេធាវីដើមបណ្តឹងឧទ្ធរណ៍:**
លោក អាង ឧត្តម
លោកMichaelG.KARNAVAS

**មេធាវីការពារក្តីដទៃទៀត:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក ផាត់ ពៅសៀង
កញ្ញា Diana ELLIS
លោក សរ សូវាន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី
លោក ឡោ ជុនធី

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING QC
ចៅក្រម ន័យ ថុល
ចៅក្រម Catherine Marchi-Uhel
ចៅក្រម ហួត វុទ្ធី

លោក Jacques VERGÈS
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

កញ្ញា SILKE Studzinsky
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យ៉ុង ផានិត
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE

## ១. សេចក្តីសង្ខេប

១. សេចក្តីសម្រេចមួយរបស់សហចៅក្រមស៊ើបអង្កេត ដូចជា ដីកាដំណោះស្រាយជាដើម[1] អាចប្តឹងឧទ្ធរណ៍នៅចំពោះមុខ អង្គបុរេជំនុំជម្រះ (អបជ) បានតែម្តងប៉ុណ្ណោះ ដោយភាគីដែលមានសិទ្ធិនិមួយៗ ។ ភាគីប្តឹងឧទ្ធរណ៍ ត្រូវលើកគ្រប់ការតវ៉ាទាំងអស់ ជំទាស់នឹងសេចក្តីសម្រេចនោះនៅក្នុងសារណាសង្ខេបមួយ[2] ។ វិធានផ្ទៃក្នុង ("វិធាន") មិនអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍ច្រើនធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍តែម្នាក់ ប្រឆាំងនឹងសេចក្តីសម្រេច ឬដីកាសម្រេចតែមួយនោះឡើយ[3] ។ បណ្តឹងឧទ្ធរណ៍មួយដោយភាគីមួយធានាបានចំពោះ ភាពសុចរិតនៃសេចក្តីសម្រេចដែលកំពុងតែតវ៉ា គឺនៅតែរក្សាបាន និងថា ការកំណត់សម្រេចជាចុងក្រោយដោយអបជក៏ត្រូវសម្រេចបានទាន់ពេលវេលា និងការសន្សំសំចៃធនធានរបស់តុលាការ។ ការអះអាងរបស់អៀង សារី ដែលថា សារណាដាច់ដោយឡែកចំនួន៣០ទំព័រ នឹងត្រូវដាក់ជូន ដើម្បីជំទាស់ទៅនឹងបញ្ហាយុត្តាធិការដាច់ដោយឡែកៗនានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ គួរតែត្រូវបានបដិសេធចោល[4] ។

---

[1] ដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស, សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី១៥ កញ្ញា ២០១០, ឯកសារលេខ: D427, ("ដីកាដំណោះស្រាយ") ។

[2] សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់សហមេធាវី ក្នុងការស្នើសុំពន្យារពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ, បណ្តឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០៣), អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៣ មីនា ២០០៨ ឯកសារលេខ: C22/I/15 កថាខ័ណ្ឌទី៣-៤ ។ នៅក្នុងករណីនេះ អៀង សារី មានបំណងតវ៉ាទៅលើតែសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ននៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ និងដើម្បីលើកពេលទៅពេលក្រោយចំពោះចម្លើយតបរបស់ខ្លួនទៅនឹងបញ្ហាយុត្តាធិការ ។ ក្រោយពីមានការពិចារណាលើសំណើនេះរួចមក អង្គបុរេជំនុំជម្រះបានរកឃើញថា មេធាវីរបស់ អៀង សារី "មានឱកាសលើកពីបញ្ហា*ទាំងអស់* ដែលគេចង់លើកនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន" ប្រឆាំងនឹងដីកាឃុំខ្លួន (សង្កត់ធ្ងន់ត្រង់អក្សរទ្រេត) ។ អង្គបុរេជំនុំជម្រះ បានរកឃើញថា គេពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង សម្រាប់អង្គជំនុំជម្រះរកឱ្យឃើញថា អៀង សារី "មានសេរីភាពដាក់ការតវ៉ាអំពីយុត្តាធិការណាមួយ [ជាបន្តបន្ទាប់] ទេ" ។

[3] *សូមអាន* វិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥ ចុះថ្ងៃទី៩ កុម្ភៈ ២០១០ ("វិធាន"), វិធាន ៧៥.៣ (ចែងថា បណ្តឹងឧទ្ធរណ៍អាចប្តឹងក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចដែលនឹងត្រូវតវ៉ានោះ) ។

[4] សំណើជាបន្ទាន់របស់ អៀង សារី សុំបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ, បណ្តឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥), ចុះថ្ងៃទី១៧ កញ្ញា ២០១០, ឯកសារលេខ: D427/1/1, ("សំណើ"), ទំព័រទី១ ។

២. ប៉ុន្តែ ការកំណត់ចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ឬដីកាសម្រេច អាច បន្ថែម និងធ្លាប់បានបន្ថែមសម្រាប់កាលៈទេសៈពិសេស[5] ។ តុលាការនេះ បានផ្តល់ឲ្យមានការបន្ថែមចំនួនទំព័រ ប្រសិនបើភាគីបានបង្ហាញឲ្យឃើញថា ការបន្ថែមនោះនឹងផ្តល់ឲ្យតុលាការនូវ "សម្ភារៈគ្រប់គ្រាន់ដើម្បីពិចារណាទៅលើគ្រប់បញ្ហាទាំងអស់ [...] បានសមស្រប"[6] ឬ ដោយសារ "សារសំខាន់ ឬ ភាពស្មុគស្មាញនៃនីតិវិធីស៊ើបសួរ និងបញ្ហាយុត្តិសាស្ត្រ"[7] ។ អៀង សារី បានស្វែងរកការបន្ថែមទំព័រមួយរហូតដល់ ១៥០ទំព័រ ដែលលើសពីចំនួន៣០ទំព័រ ដូចបានចែងកំណត់នៅក្នុងវិធាន[8] ដោយឈរលើមូលដ្ឋានថា ដីកាដំណោះស្រាយ (១) "លើកពីបញ្ហានៃយុត្តាធិការមួយចំនួន" និង (២) "បញ្ហានិមួយៗទាំងនេះគឺពិតជាស្មុគស្មាញ ហើយបញ្ហានិមួយៗសឹងតែប្រើអស់សាបសិបទំព័រទៅហើយ បើសិនជាសំណើសុំបង្កើនចំនួនទំព័រនេះ មិនត្រូវបានអនុញ្ញាតនោះ"[9] ។ ដូចដែលដីកាដំណោះស្រាយលើកឡើងអំពីបញ្ហាយុត្តាធិការមួយចំនួន ការបន្ថែមចំនួនទំព័រកំណត់ដ៏សមស្របនឹងស្ថិតនៅជាផលប្រយោជន៍នៃយុត្តិធម៌ ។ ទោះជាយ៉ាងនេះក្តី ការបន្ថែមចំនួនទំព័ររហូតដល់ទៅចំនួនមួយរយប៉ែតសិប(១៨០ ទំព័រ) គឺប្រាំមួយ (៦) ដងលើសពីអ្វីដែលសេចក្តីណែនាំអនុវត្តបានរំពឹងទុកនោះ គឺវាមានលក្ខណៈលើសលុប ហើយគួរតែត្រូវបានបដិសេធចោល។

៣. តាមការប្រៀបធៀប សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ("សេចក្តីណែនាំអនុវត្ត") ចំពោះបណ្តឹងសាទុក្ខដែលជំទាស់ទៅនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឲ្យដាក់ចំនួនអតិបរមា សាមសិប(៣០ ទំព័រ) ដែលដូចគ្នាទៅនឹងដីកាដំណោះស្រាយ ដែលទាក់ទងទៅនឹងសេចក្តីសន្និដ្ឋាននានាតាមអង្គហេតុ និងអង្គច្បាប់ជាច្រើន ដែលបានលើកឡើងនៅពេញមួយដំណើរការសវនាការ[10] ។ តុលាការអន្តរជាតិដទៃទៀត ដូចជាតុលាការព្រហ្មទណ្ឌ

---

[5] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី៤, ចុះថ្ងៃទី៥ មិថុនា ២០០៩ ("សេចក្តីណែនាំអនុវត្ត"), មាត្រា៥.៤ ។

[6] សេចក្តីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ របស់សហព្រះរាជអាជ្ញា ក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ប្រឆាំងនឹងដីកាសម្រេចស្តីពីសហកម្មឧក្រិដ្ឋកម្មរួម បណ្តឹងឧទ្ធរណ៍លេខ: បណ្តឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៣៥, ៣៧, ៣៨ និង ៣៩), អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៩ កុម្ភៈ ២០១០ ("សេចក្តីសម្រេច របស់ អបជ អំពី JCE") កថាខ័ណ្ឌទី៦ ។

[7] ដីកាសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រកំណត់ សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ កញ្ញា ២០០៩ កថាខ័ណ្ឌទី៨ ។

[8] សេចក្តីណែនាំអនុវត្ត មាត្រា៥.២ សំណើសុំ ទំព័រទី២ ។

[9] សំណើ ទំព័រទី១ ។

[10] សេចក្តីណែនាំអនុវត្ត មាត្រា ៥.២ ។

00609975



អន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវីជាដើម ក៏បានចែងពីចំនួនទំព័រដែលខ្លីជាងឆ្ងាយពីចំនួនទំព័រដែល អៀង សារី បានធ្វើការស្វែងរក ។ ជាឧទាហរណ៍ ចំនួនប្រាំបួនពាន់ (៩ ០០០ ពាក្យ) ឬសាមសិប(៣០ ទំព័រ) សម្រាប់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំចំនួនបីម៉ឺន (៣០ ០០០ ពាក្យ) ឬមួយរយ (១០០ ទំព័រ) សម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រម និងចំនួនមួយម៉ឺនពីរពាន់ (១២ ០០០ ពាក្យ) ឬសែសិប(៤០ទំព័រ) បើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រមមួយត្រូវបានកំរិតត្រឹមតែការផ្តន្ទាទោស[11] ។ សំណើរបស់ អៀង សារី ដែលស្នើសុំចំនួនមួយរយប៉ែតសិប (១៨០ ទំព័រ) គឺលើសឆ្ងាយពីកំរិត ដែលត្រូវបានទទួលស្គាល់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍នៅក្នុងដំណាក់ការជំនុំជម្រះមុនអង្គសេចក្តី និងនៅក្នុងដំណាក់ការបណ្តឹងសាទុក្ខ នៅតាមយុត្តាធិការអន្តរជាតិផ្សេងៗទៀត ។

៤. លើសពីនេះទៀត សំណើសុំបន្ថែមចំនួនទំព័រនេះក៏មានលក្ខណៈលើសលុបផងដែរ កាលណាគេពិចារណាថា វិធានពុំមានបំណងធ្វើឱ្យដីកាដំណោះស្រាយទាំងមូលនេះ អាចត្រូវបានប្តឹងឧទ្ធរណ៍ពីសំណាក់មេធាវីការពារក្តីទេ ។ ទោះបីជា អបជ បានលើកឡើងពីលទ្ធភាព ដែលបណ្តឹងឧទ្ធរណ៍មួយ ពីសំណាក់មេធាវីការពារក្តីអាចនឹងត្រូវបានដាក់ "បើដីកាដំណោះស្រាយបញ្ជាក់ពីយុត្តាធិការរបស់អវតក" ដូច្នោះ ជនដែលត្រូវបញ្ជូនទៅជំនុំជម្រះ "អាចនឹងពិចារណាពីអានុភាពនៃវិធាន ៦៧.៥ នៃវិធានផ្ទៃក្នុង [ដែលពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ] កាលណាអាន ជាមួយគ្នានឹងវិធាន៧៤.៣.ក នៃវិធានផ្ទៃក្នុង [ដែលពាក់ព័ន្ធទៅនឹងលទ្ធភាពនៃបណ្តឹងឧទ្ធរណ៍មួយ បើសេចក្តីសម្រេចបញ្ជាក់ពីពីយុត្តាធិការរបស់អវតក]"[12] ក៏ដោយក៏ អបជ ពុំធ្លាប់បានបញ្ជាក់ ថាតើនៅក្នុងកាលៈទេសៈណា ដែលបណ្តឹងឧទ្ធរណ៍បែបដូច្នេះអាចនឹងទទួលយកបាននោះទេ។ សហព្រះរាជអាជ្ញា យល់ឃើញថា បើសិនជាបញ្ហាស្តីពីយុត្តាធិការដែលមានបំណងលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ណាមួយក៏ដោយ ត្រូវបានបញ្ជាក់ពីពេលមុនដោយសហចៅក្រមស៊ើបអង្កេត ហើយថា ដើមបណ្តឹងឧទ្ធរណ៍នោះ មិនដែលបានជ្រើសរើសធ្វើការប្តឹងឧទ្ធរណ៍ ពីបញ្ហាយុត្តាធិការនោះតាំងពី

[11] សេចក្តីណែនាំអនុវត្ត ស្តីពីចំនួនទំព័រក្នុងការដាក់សារណា និងញត្តិ IT/184.Rev.2 ថ្ងៃទី១៦ កញ្ញា ២០០៥ មាត្រា គ.១ គ.២ ។

[12] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ បណ្តឹងឧទ្ធរណ៍លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-៦០) អង្គបុរេជំនុំជម្រះ ថ្ងៃទី៩ មិថុនា ២០១០ ឯកសារលេខ: D345/5/11 កថាខណ្ឌទី ១១ ។

ដំណាក់ការមុនមកទេ នោះជាលទ្ធផល ពួកគាត់នឹងអស់ពេលក្នុងការលើកឡើងពីបញ្ហាទាំងនោះក្នុងពេលនេះហើយ ។ ផ្ទុយទៅវិញ បើអនុញ្ញាតឱ្យ នោះមុខជានឹងមានការរំលោភទៅលើនីតិវិធីរបស់ អបជ និងនាំឱ្យខូចខាតលើវិស័យគ្រប់គ្រងយុត្តិធម៌ ជាមិនខាន ។

៥. សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ អំពីយុត្តាធិការទៅលើជនទាំងបួនរូបបច្ចុប្បន្នដែលកំពុងត្រូវបានចោទប្រកាន់ដែលរួមទាំង អៀងសារីផង នៅក្នុងអម្លុងខែកញ្ញា-វិច្ឆិកាឆ្នាំ ២០០៧ នៅពេលដែលសហចៅក្រមបានបង្គាប់ឱ្យចាប់ខ្លួនពួកគេនិងបញ្ជូនទៅចំពោះមុខ អវតក និងដាក់ឱ្យពួកគេស្ថិតក្រោមកិច្ចស៊ើបសួររយៈពេលបីឆ្នាំ ។ ជាក់ច្បាស់ជាងនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការរបស់តុលាការនេះទៅលើ អៀង សារី កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧នៅពេលសហចៅក្រមស៊ើបអង្កេតបានឃុំខ្លួនជននេះពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ[13]។

៦. យុត្តាធិការត្រូវបានធ្វើការបញ្ជាក់ជាបន្ថែមទៀតទៅលើ អៀង សារីកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ នៅពេលដែលសហចៅក្រមស៊ើបអង្កេត បានជូនដំណឹងឱ្យគាត់ជ្រាបពីបទចោទប្រកាន់នានាក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងក្រោមអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[14]។ នៅក្នុងលិខិតទាក់ទងរបស់ខ្លួនចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់ផងដែរអំពីយុត្តាធិការរបស់ អវតក ទៅលើ អៀង សារី ទាក់ទងទៅនឹងវិធីនៃការទទួលខុសត្រូវក្នុងការធ្វើផែនការ ការញុះញង់ បញ្ជា ប្រព្រឹត្ត ការជួយនិងការទំនុកបំរុង សមគំនិត ចូលរួម ប៉ុនប៉ងសហកម្មឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ[15]។ អៀង សារី មានពេលវេលាកំណត់សាមសិបថ្ងៃសម្រាប់ឱ្យធ្វើការតវ៉ាជំទាស់ទៅនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ[16]។

---

[13] ដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៤ វិច្ឆិកា ២០០៧ ទំព័រ ១-២ និងទំព័រ ៧។

[14] កំណត់ហេតុសួរចម្លើយជនត្រូវចោទ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ធ្នូ ២០០៩ ( "កំណត់ហេតុថ្ងៃទី១៦ ធ្នូ ២០០៩") កថាខណ្ឌទី ៩-១៣។

[15] កំណត់ហេតុថ្ងៃទី១៦ ធ្នូ ២០០៩ កថាខណ្ឌទី ៩។

[16] វិធាន៧៥.៣ នៃវិធានផ្ទៃក្នុង។

៧. ជាជាងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាំងអស់ដែលបញ្ជាក់អំពីយុត្តាធិការ អៀង សារី បែរជាជ្រើសរើសយកការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ទៅវិញ ៖ (១) លើបញ្ហាស្តីពីការលើកលែងទោសដោយព្រះមហាក្សត្រ និងការអត់ឱនទោសដែលត្រូវបានអនុញ្ញាតចំពោះរូបគាត់ និង(២) ដោយហេតុផលអំពីការកាត់ក្តីពីរដងលើបទល្មើសតែមួយដដែល ដោយសារគាត់ត្រូវបាន "កាត់ឱ្យមានទោស" ដោយតុលាការប្រជាជនបដិវត្តពីឆ្នាំ១៩៧៩ រួចម្តងហើយ[17]។ ហេតុដូចនេះ ប្រការដែល អៀង សារី មិនបានធ្វើការតវ៉ាជំទាស់នឹងដីកាសម្រេចចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ និងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩នោះ គឺគាត់បានលះបង់ចោលនូវសិទ្ធិរបស់គាត់ក្នុងការតវ៉ាជំទាស់ ទៅនឹងយុត្តាធិការលើគ្រប់រាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងយុត្តាធិការ ដែលបានបញ្ជាក់ដោយដីកាសម្រេចទាំងនោះហើយ នៅក្នុងអម្លុងពេលនៃដំណើរការនីតិវិធីនៅមុនពេលសវនាការជំនុំជម្រះក្តី នៅចំពោះមុខ អបជ ។ ក៏ប៉ុន្តែ នៅក្នុងពេលសវនាការ គាត់អាចមានសិទ្ធនៅក្នុងការលើកឡើងអំពី "ការបដិសេធបឋមនានា" បាន ដែលរួមទាំងបញ្ហាអំពីយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូងផងក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីដីកាដំណោះស្រាយបានចូល ជាស្ថាពរ[18] ។

## II. សេចក្តីសន្និដ្ឋាន

៨. ដោយ (១) ដីកាដំណោះស្រាយ គ្រាន់តែបានលើកឡើងជាថ្មីនូវការប្រើប្រាស់យុត្តាធិការដែលត្រូវបានបញ្ជាក់ ដោយសហចៅក្រមស៊ើបអង្កេត *ក្នុងចំណោមបញ្ហាដទៃទៀត* ដោយសេចក្តីសំរេចរបស់ខ្លួននាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ និងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ (២) កាលពីអតីតកាលអៀង សារី មានឱកាសតវ៉ាបញ្ជាក់អំពីយុត្តាធិការនោះ ដែលរូបគាត់បានជ្រើសរើសយកមកប្រើ (៣) អៀង សារី ធ្លាប់បានធ្វើការប្តឹងយ៉ាងសន្ធឹកសន្ធាប់ និងដោយដដែលៗជាច្រើនដងរួចមកហើយ សេចក្តីសង្ខេបស្តីពីបញ្ហានានា ក្នុងនេះរួមមាន តែមិនកម្រិតតែត្រឹមគ្រោះថ្នាក់ទ្វេដងទេ អំពីបញ្ហាការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឧក្រិដ្ឋកម្មចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សហកម្មឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវក្នុងការចេញបញ្ជា ហើយឯកសារទាំងនេះស្ថិតនៅក្នុងសំណុំរឿងនៅឡើយ និង (៤) អបជ និងអង្គជំនុំជម្រះសាលាដំបូង បានយកមកប្រើយ៉ាងទូលំទូលាយ ក្នុងឱកាសផ្សេងៗគ្នាជាច្រើន ចំពោះបញ្ហាទាំង

[17] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការឃុំខ្លួន អៀង សារី បណ្តោះអាសន្ន បណ្តឹងឧទ្ធរណ៍សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ០៣) អង្គបុរេជំនុំជម្រះ,ចុះថ្ងៃទី១៧ តុលា ២០០៨ ឯកសារលេខ C22/I/74 ។

[18] វិធាន៨៩ នៃវិធានផ្ទៃក្នុង។

អស់នេះ វាជាការមិនសមហេតុសមផលផង និងនាំឱ្យមានជម្លោះរដ្ឋបាលយុត្តិធម៌ផងបើផ្តល់ឱ្យ អៀង សារី នូវការស្នើសុំការពង្រីកការកម្រិតចំនួនទំព័ររហូតដល់១៨០ទំព័រនោះ[19]។

៩. ទោះបីយ៉ាងនេះក្តី ក៏ការពង្រីកដោយសមហេតុផលមួយនៅតែអាចធ្វើទៅបាន ដើម្បីឱ្យ អៀង សារី មានលទ្ធភាពអាច" ផ្តល់ដល់ អង្គ[បុរេជំនុំជម្រះ] នូវសម្ភារៈគ្រប់គ្រាន់ដើម្បីពិចារណាលើបញ្ហាទាំងអស់ [...] បានដោយសមស្រប[20] ។ សហព្រះរាជអាជ្ញា ពិចារណាថា ការអនុញ្ញាតឱ្យពង្រីកចំនួនទំព័រទ្វេដងនៃការពង្រីកចំនួន៣០ទំព័រ គឺជាការពង្រីកដ៏សមស្របហើយ ។ ក្នុងស្ថានភាពបែបនេះ សហព្រះរាជអាជ្ញា មិនប្រឆាំងចំពោះការពង្រីកការកម្រិតព្រំដែននៃចំនួនទំព័រទេ តែសុំថា អបជផ្តល់ដល់ការស្នើសុំជាផ្នែក ដោយការពង្រីកការកម្រិតព្រំដែននៃចំនួនទំព័រនៃការស្នើសុំដោយ ដើមបណ្តឹងឧទ្ធរណ៍ឱ្យសង្ខេបដល់អតិបរមាត្រឹមចំនួន៦០ទំព័រជាភាសាអង់គ្លេសប៉ុណ្ណោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[19] *សូមមើល ក្នុងចំណោមបញ្ហាដទៃទៀត* សាលក្រម លើសំណុំរឿងលេខ 001/18-07-2007-ECCC-TC, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ E188 (ទាក់នឹងបញ្ហាចំនួន៤ ក្នុងចំណោមបញ្ហា៧ លើកឡើងដោយ អៀង សារី ពោលគឺ (១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២) ការរំលោភយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ (៣) ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង (៤) ការទទួលខុសត្រូវក្នុងការចេញបញ្ជា) ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហកម្មឧក្រិដ្ឋកម្មរួម បណ្តឹងឧទ្ធរណ៍លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ៣៨) D97/15/9, ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ (ទាក់ទងនឹងបញ្ហាយុត្តាធិការរួមជាច្រើន ទៅនឹងបញ្ហាទាំងអស់ លើកឡើងដោយ អៀង សារី ថាជាចំណុចនៃបណ្តឹងឧទ្ធរណ៍ជាសក្តានុពលរបស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ) ។

[20] សេចក្តីសំរេចរបស់ អបជ ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម កថាខ័ណ្ឌ ៦ ។